# ការវិភាគផ្លូវច្បាប់ជុំវិញការឃុំខ្លួនបណ្ដោះអាសន្នលើលោក នី សុខា លោក យី សុខសាន្ត លោក ណៃ វ៉ង់ដា លោកស្រី លឹម មុនី និងលោក នី ចរិយា

ខែវិច្ឆិកា ឆ្នាំ២០១៦

## ១. សេចក្ដីផ្ដើម

លោក នី សុខា លោក យី សុខសាន្ត លោក ណៃ វ៉ង់ដា និងលោកស្រី លឹម មុនី ដែលជាបុគ្គលិកជាន់ខ្ពស់បួនរូបរបស់សមាគមអាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ("សមាគមអាដហុក") និងលោក នី ចរិយា អតីតបុគ្គលិករបស់សមាគមអាដហុក និងជាអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានឃុំខ្លួនតាំងពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ។ ពួកគាត់ត្រូវបានចោទប្រកាន់ពីបទសូកប៉ាន់សាក្សី តាមមាត្រា ៥៤៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ហើយលោក នី ចរិយា ត្រូវបានចោទប្រកាន់ពីបទសមគំនិតនៅក្នុងបទល្មើសដូចគ្នា។

នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ជាថ្ងៃគម្រប់ចំនួន ២០០ ថ្ងៃនៃការឃុំខ្លួនបណ្ដោះអាសន្នសម្រាប់អ្នកការពារសិទ្ធិមនុស្ស ("អ្នកការពារសិទ្ធិមនុស្ស") ទាំងប្រាំ។ ដើម្បីរម្លឹកដល់ហេតុការណ៍ដែលគួរឱ្យសោកស្ដាយនេះ និងមុនពេលដែលតុលាការកំពូលនឹងបើកសវនាការលើបណ្ដឹងរបស់អ្នកទាំងប្រាំប្ដឹងសារទុក្ខជំទាស់នឹងសេចក្ដីសម្រេចបដិសេធឱ្យនៅក្រៅឃុំកាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ការវិភាគផ្លូវច្បាប់នេះនឹងពិនិត្យមើលថាតើការបន្តឃុំខ្លួនបណ្ដោះអាសន្នលើអ្នកការពារសិទ្ធិមនុស្សទាំងប្រាំនាក់អនុលោមតាមបទដ្ឋានគតិយុត្តដែលកំពុងអនុវត្តមានហេតុផលសមរម្យ និងមានភស្តុតាងគ្រប់គ្រាន់សម្រាប់គាំទ្រសេចក្ដីសម្រេចឬយ៉ាងណា។

ការវិភាគផ្លូវច្បាប់រួមគ្នានេះចេញផ្សាយដោយអង្គរួមមាន ៖ ក្រុមការងារដើម្បីដោះស្រាយទំនាស់ ("ក.ដ.ទ") អនាគតយុវជនកម្ពុជាអាស៊ាន ("អ.យ.ក.អ") មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") សមាគមអាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ("សមាគមអាដហុក") គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ("ខុមហ្វ្រែល") មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ ("ម.អ.ច.ស") អង្គការ យេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា ("អ.យ.អ.ក") ក្រុមការងារពិសេសសិទ្ធិលំនៅឋាន ("ក.ព.ស.ល") ជំនួយផ្នែកច្បាប់នៃកម្ពុជា ("ជ.ច.ក") អង្គការពន្លកខ្មែរ ("អ.ព.ខ") អង្គការស្ត្រីខ្មែរ ("អ.ស.ខ") និងអង្គការពិភពលោកប្រឆាំងទារុណកម្ម ("អ.ព.ប.ទ")។

## ២. អង្គហេតុ

បទចោទទាំងនេះពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតរបស់អង្គភាពប្រឆាំងអំពើពុករលួយទៅលើការប្រកាន់ពីទំនាក់ទំនងស្នេហារវាងលោក កឹម សុខា ប្រធានស្តីទីគណៈបក្សសង្គ្រោះជាតិ នឹងកញ្ញា ខុម ចាន់តារ៉ាទី។ ក្នុងតួនាទីរបស់ខ្លួនជាអ្នកធ្វើការផ្នែកសិទ្ធិមនុស្ស បុគ្គលិករបស់សមាគមអាដហុកបានផ្តល់ជំនួយផ្នែកច្បាប់ និងសម្ភារៈត្រឹមត្រូវតាមច្បាប់ និងជាប់ជាប្រចាំទៅដល់កញ្ញា ចាន់តារ៉ាទី ដែលបានស្នើសុំជំនួយពីសមាគមអាដហុក ក្រោយពីខ្លួនស្ថិតក្រោមការស៊ើបអង្កេតដោយសារតែមានការចោទប្រកាន់ពីទំនាក់ទំនងស្នេហា។ ទោះជាយ៉ាងនេះក៏ដោយ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ កញ្ញា ចាន់តារ៉ាទី បានអះអាងក្នុងលិខិតចំហមួយថាអ្នកការពារសិទ្ធិមនុស្សទាំងប្រាំរូបបានបញ្ចុះបញ្ចូលនាងឱ្យនិយាយកុហកនៅក្នុងដំណើរការនៃការស៊ើបអង្កេត។

លោក នី សុខា លោក យី សុខសាន្ត និងលោក ណៃ វ៉ង់ដា ត្រូវបានកោះហៅលើកដំបូងទៅការិយាល័យអង្គភាពប្រឆាំងអំពើពុករលួយនៅថ្ងៃពុធ ទី២៧ ខែមេសា ឆ្នាំ២០១៦ និងត្រូវបានសួរចម្លើយដោយបន្លាយពេលវេលាយ៉ាងយូរ។ អ្នកទាំងបីត្រូវបានដោះលែងនៅប្រហែលជាម៉ោង១១យប់នៅថ្ងៃដដែល ប៉ុន្តែរងការគំរាមថានឹងត្រូវចាប់ខ្លួនប្រសិនបើពួកគេមិនបង្ហាញខ្លួននៅម៉ោង៨ព្រឹកនាថ្ងៃបន្ទាប់ដើម្បីបន្តការសាកសួរ។ លោក នី ចរិយា និងលោកស្រី លឹម មុនី ក៏ត្រូវបានសាកសួរនៅថ្ងៃព្រហស្បតិ៍ ទី២៨ ខែមេសា ឆ្នាំ២០១៦ ហើយក្រោយមកនៅក្នុងថ្ងៃដដែលនេះ អ្នកការពារសិទ្ធិមនុស្សទាំងប្រាំត្រូវបានឃុំខ្លួន។ អ្នកការពារសិទ្ធិមនុស្សទាំងប្រាំត្រូវបានឃុំខ្លួនដោយគ្មានការចោទប្រកាន់ រហូតដល់ថ្ងៃទីថ្ងៃច័ន្ទ ទី២ ខែឧសភា ឆ្នាំ២០១៦ នៅពេលដែលពួកគាត់ត្រូវបានចោទប្រកាន់នៅពេលរសៀល។

មេធាវីរបស់ជនជាប់ឃុំទាំងនេះបានដាក់ពាក្យសុំនៅក្រៅឃុំទៅកាន់សាលាដំបូងរាជធានីភ្នំពេញនៅថ្ងៃទី១៦ ខែឧសភា ប៉ុន្តែពាក្យសុំនេះត្រូវបានបដិសេធទៅថ្ងៃបន្ទាប់ គឺថ្ងៃទី១៧ ខែឧសភា។ ពាក្យសុំនៅក្រៅឃុំរបស់អ្នកទាំងប្រាំត្រូវបានបដិសេធដោយសាលាឧទ្ធរណ៍នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦។ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ បណ្តឹងសារទុក្ខទាក់ទិននឹងការបដិសេធឱ្យនៅក្រៅឃុំត្រូវបានប្តឹងទៅតុលាការកំពូល។ សវនាការអេសាធារណៈនៃបណ្តឹងសារទុក្ខនឹងធ្វើឡើងនៅថ្ងៃទី២៣ ខែវិច្ឆិកា បន្ទាប់ពីការអូសបន្លាយរយៈពេលជាង៥ខែ។

សវនាការអេសាធារណៈលើបណ្តឹងឧទ្ធរណ៍របស់អ្នកទាំងប្រាំប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ដើម្បីបន្តឃុំខ្លួនបណ្តោះអាសន្នរយៈពេល ៦ ខែបន្ថែមទៀតនោះបានប្រព្រឹត្តទៅនៅសាលាឧទ្ធរណ៍កាលពីថ្ងៃទី១១ ខែវិច្ឆិកា។ សាលាឧទ្ធរណ៍បានតម្កល់សេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ។ ការវិភាគខាងក្រោមក៏ទាក់ទងទៅនឹងបណ្តឹងឧទ្ធរណ៍នេះផងដែរ។

## ៣. អន្តច្បាប់

### ៣.១. ច្បាប់សិទ្ធិមនុស្សអន្តរជាតិ

ទោះបីជាពេលខ្លះវាមានភាពចាំបាច់សម្រាប់ការឃុំខ្លួនបណ្ដោះអាសន្ន ដើម្បីជួយសម្រួលដល់ការគ្រប់គ្រងយុត្តិធម៌ និងការពារជនរងគ្រោះ និងសាក្សីក៏ដោយ ក៏ការអនុវត្តការឃុំខ្លួនបណ្ដោះអាសន្នហួលប្រមាណ ឬមិនត្រឹមត្រូវធ្វើឱ្យមានការរឹតត្បិតមិនត្រឹមត្រូវលើសិទ្ធិមានសេរីភាព និងការសន្មតទុកជាមុនថាគ្មានទោស។

**សិទ្ធិមានសេរីភាព**ត្រូវបានការពារយ៉ាងរឹងមាំនៅក្នុងច្បាប់ជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិមានអានុភាពអនុវត្តដោយផ្ទាល់នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ដូចដែលមានបញ្ញត្តនៅក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ និងសេចក្ដីសម្រេចឆ្នាំ២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញ។[1] មាត្រា ៩(១) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") ដែលកម្ពុជាជារដ្ឋភាគីចែងថា ៖

> *"ជនគ្រប់រូប មានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ។ គ្មានជនណាម្នាក់ ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់"។*

មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញបញ្ញត្តស្រដៀងគ្នានេះដែរថា *"ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួនឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។"* នៅពេលជនណាមួយត្រូវបានឃុំខ្លួនដោយមិនអនុលោមទៅតាមច្បាប់ជាតិ នោះការឃុំខ្លួនរបស់ពួកគេគឺមិនត្រឹមត្រូវតាមច្បាប់ និងតាមអំពើចិត្តដោយរំលោភបំពានដល់រដ្ឋធម្មនុញ្ញ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

**សិទ្ធិទទួលបានការជំនុំជម្រះក្នុងរយៈពេលសមស្រប និងសិទ្ធិទទួលបានសម្អាងហេតុត្រឹមត្រូវដ៏រឹងមាំលើការសម្រេចឃុំខ្លួនបណ្ដោះអាសន្ន** ក៏ត្រូវបានការពារយ៉ាងរឹងមាំក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ មាត្រា ៩(៣) នៃ ("ក.អ.ស.ព.ន") បញ្ញត្តថា ៖

> *"បុគ្គលណាដែលបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ នឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ឱ្យបំពេញមុខងារតុលាការ ក្នុងរយៈពេលយ៉ាងខ្លីបំផុត និងត្រូវបានជំនុំជម្រះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង។ ការឃុំ*

[1] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, សេចក្ដីសម្រេចលេខ ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧)។

*ខ្លួនមនុស្ស ដើម្បីរង់ចាំការជំនុំជម្រះ គឺមិនមែនជាវិធានទូទៅទេ ប៉ុន្តែការឱ្យនៅក្រៅឃុំ ត្រូវតែមានការធានាការចូលខ្លួនរបស់ជននោះ នៅពេលសវនាការ ឬនៅគ្រប់ដំណាក់កាលដទៃទៀតនៃនីតិវិធី ហើយត្រូវមានមុខក្នុងការអនុវត្តសាលក្រម"។*

ដូច្នេះ ប្រសិនបើការត្រួតពិនិត្យតាមផ្លូវតុលាការ ឬវិធានការផ្សេងទៀតមិនអាចឆ្លើយតបទៅនឹងការព្រួយបារម្ភទាំងឡាយ ហើយការឃុំខ្លួនជនត្រូវចោទត្រូវបានកំណត់ថាពិតជាចាំបាច់មែននោះ ទើបការឃុំខ្លួនបណ្ដោះអាសន្នត្រូវពិចារណាជាជម្រើសចុងក្រោយ។ សេរីភាពជនជាប់ចោទគួរតែជាជម្រើសចម្បង ជាជាងការឃុំខ្លួន។

គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ("អ.ស.ប") ដែលជាស្ថាប័នទទួលបន្ទុកលើការអនុវត្តសន្ធិសញ្ញា ដែលអាចធ្វើការបកស្រាយដែលមានលក្ខណៈបង្គាប់បញ្ជាលើ ក.អ.ស.ព.ន បានបកស្រាយថាដើម្បីបង្ហាញសម្អាងហេតុដ៏ត្រឹមត្រូវចំពោះការលើកលែងការអនុវត្តវិធានទូទៅ ដែលជនណាម្នាក់កំពុងរង់ចាំការជុំនំជម្រះមិនត្រូវស្ថិតនៅក្នុងការឃុំខ្លួន រដ្ឋត្រូវបង្ហាញឱ្យបានគ្រប់គ្រាន់ពីក្ដីកង្វល់ដែលជាសម្អាងហេតុដល់ការបន្តការឃុំខ្លួន និងពីមូលហេតុដែលថាការព្រួយបារម្ភទាំងនោះនឹងមិនអាចដោះស្រាយបានតាមរយៈការដោះលែងឱ្យនៅក្រៅឃុំបាននោះទេ។[2]

**សិទ្ធិសន្មតទុកជាមុនថាគ្មានទោស** ដែលជាធាតុសំខាន់មួយនៃសិទ្ធិទទួលបានការជុំនំជម្រះដោយយុត្តិធម៌ ក៏ត្រូវបានការពារក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់ជាតិផងដែរ។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានបញ្ញត្តថា ៖

*"ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"។*

មាត្រា ១៤(២) នៃ ក.អ.ស.ព.ន បញ្ញត្តថា ៖

*"ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌត្រូវបានសន្មតទុកជាមុនថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួន ត្រូវបានកំណត់តាមច្បាប់ "។*

ចំណុចនេះរួមបញ្ចូលទាំងភារកិច្ចរបស់អាជ្ញាធរសាធារណៈទាំងឡាយមិនត្រូវធ្វើការវិនិច្ឆ័យទុកជាមុននូវលទ្ធផលនៃសវនាការ ឧទាហរណ៍ដូចជាការចៀសវាងការធ្វើសេចក្ដីថ្លែងការណ៍ជាសាធារណៈដែលបញ្ជាក់ពីពិរុទ្ធភាពនៃជនជាប់ចោទជាដើម។[3] ការឃុំខ្លួនបណ្ដោះអាសន្នហួសហេតុអាចធ្វើឱ្យប៉ះពាល់ដល់ការសន្មតទុកជាមុនថាគ្មានទោសតាមរយៈការដាក់ទណ្ឌកម្មលើជនត្រូវចោទ មុនពេលដែលពួកគេត្រូវបានជំនុំជម្រះ និងផ្ដន្ទាទោសដោយ

---

[2] ស្មានស្ទ័រ និង បែលឡារ៉ូស, គណៈម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ (ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៨) កថាខណ្ឌទី១០.៣។

[3] គណៈម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ, យោបល់ជាទូទៅលេខ ៣២, ផ្នែកទី៤។

តុលាការ ឬតាមរយៈការបង្កើតឱ្យមានការយល់ច្រលំថាពួកគេត្រូវបានគេចាត់ទុករួចទៅហើយថាជាឧក្រិដ្ឋជនដ៏គ្រោះថ្នាក់ដែលត្រូវតែឃុំខ្លួន។

## ៣.២. ច្បាប់ជាតិ

មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌបញ្ញត្តថា ការឃុំខ្លួនបណ្ដោះអាសន្នអាចធ្វើឡើងតែក្នុងករណី ចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលអាចត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារស្មើមួយឆ្នាំ ឬច្រើនជាងមួយឆ្នាំ។ ដោយសារតែបទសូកប៉ាន់សាក្សីក្នុងមាត្រា ៥៤៨ នៃក្រមព្រហ្មទណ្ឌអាចត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពីប្រាំឆ្នាំដល់ដប់ឆ្នាំ ទាំងសម្រាប់អ្នកផ្ដើមគំនិត និងអ្នកសមគំនិត ជាគោលការណ៍ការឃុំខ្លួនបណ្ដោះអាសន្នសម្រាប់ករណីនេះអាចធ្វើទៅបាន។

ក្រមនីតិវិធីព្រហ្មទណ្ឌបញ្ញត្តយ៉ាងច្បាស់ក្នុងមាត្រា ២០៣ ថា ជម្រើសដំបូងគួរតែថាជនត្រូវចោទត្រូវមានសេរីភាព មានតែករណីលើកលែងពិសេសប៉ុណ្ណោះដែលជនត្រូវចោទអាចត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន។ បើជនត្រូវចោទត្រូវឃុំខ្លួនមែននោះ ការឃុំខ្លួនត្រូវតែអនុលោមតាមលក្ខខណ្ឌដែលបានបញ្ញត្តនៅក្នុងផ្នែកដែលរៀបរាប់អំពីការឃុំខ្លួនបណ្ដោះអាសន្ននៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដូច្នេះ ក្រមនីតិវិធីព្រហ្មទណ្ឌបញ្ជាក់យ៉ាងច្បាស់ថាការឃុំខ្លួនបណ្ដោះអាសន្នត្រូវអនុវត្តជាជម្រើសចុងក្រោយ ហើយចៅក្រមគួរចាប់ផ្ដើមពីការសន្មតថាជនជាប់ចោទគ្រប់រូបគួរត្រូវដោះលែងឱ្យមានសេរីភាពរហូតដល់ពេលជំនុំជម្រះ ឬក៏គួរពិចារណាដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ (ការដាក់លក្ខខណ្ឌលើសេរីភាពជនត្រូវចោទរហូតដល់ពេលសវនាការ) មុនពេលដែលចៅក្រមពិចារណាពីការអនុវត្តការឃុំខ្លួនបណ្ដោះអាសន្ន។

គួរឱ្យសោកស្ដាយ កម្ពុជានៅតែបន្តមានអត្រានៃការឃុំខ្លួនបណ្ដោះអាសន្នខ្ពស់នៅឡើយ។[4] តួលេខថ្មីៗដែលចេញផ្សាយដោយអគ្គនាយកដ្ឋានពន្ធនាគារបានផ្ដល់តួលេខអ្នកជាប់ពន្ធនាគារមានចំនួន ២១.៧០០ នាក់ (០,១៤% នៃចំនួនប្រជាជនសរុប)។ ចំនួននេះជាការកើនឡើង ១២៥% នៃចំនួនអ្នកជាប់ពន្ធនាគារនៃតួលេខឆ្នាំ ២០០៦ ដែលមាន ៩.៦៣៤ នាក់។[5] ហេតុផលមួយនៃការកើនឡើងនេះអាចដោយសារតែការឃុំខ្លួនបណ្ដោះអាសន្នមានចំនួនច្រើន និងការបង្កើនរយៈពេលកាន់តែវែងនៃការឃុំខ្លួននៅពេលតុលាការសម្រេចអនុវត្តវិធានឃុំ

---

[4] នៅឆ្នាំ២០១២ ចំនួន ៧០% នៃសវនាការដែលសង្កេតការណ៍ដោយ ម.ស.ម.ក ជនត្រូវចោទត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន, របាយការណ៍របស់ ម.ស.ម.ក, "របាយការណ៍ប្រចាំឆមាសលើកទី៥ ៖ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា" ខែវិច្ឆិកា ឆ្នាំ២០១២ http://bit.ly/2fvKnzN ។ ថ្មីៗនេះ អ្នកសង្កេតនៅខាងក្រៅបានបង្ហាញថាការឃុំខ្លួនបណ្ដោះអាសន្ននៅពន្ធនាគារកម្ពុជាមានអត្រាភាគរយខ្ពស់ដល់ទៅ ៦៣,៦% ដែលជាតួលេខខ្ពស់បំផុតក្នុងចំណោមប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍, អាលីស គូឌី និង ឆាយ ចាន់នីដា "រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អំពាវនាវឱ្យមានតម្លាភាព និងប្រសិទ្ធភាពក្នុងការឃុំខ្លួនមុនការជំនុំជម្រះក្ដី", ភ្នំពេញប៉ុស្ដិ៍, (ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥) http://bit.ly/1QDBfDm

[5] ដែក ដេវីស, "អត្រាអ្នកជាប់ឃុំក្នុងពន្ធនាគារបានកើនឡើងទ្វេដង" ភ្នំពេញប៉ុស្ដិ៍, (ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៦) http://bit.ly/2e7pyet

ខ្លួន។ ការអនុវត្តការឃុំខ្លួនបណ្ដោះអាសន្នកើតឡើងជាទូទៅលើអ្នកការពារសិទ្ធិមនុស្ស ដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ព្រមទាំងជាការរារាំងអ្នកទាំងនេះពីការធ្វើការផ្នែកសិទ្ធិមនុស្សដ៏ត្រឹមត្រូវរបស់ខ្លួន។

មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកំណត់នូវស្ថានភាពចំនួនប្រាំមួយ ដែលអាចបង្ហាញពីភាពត្រឹមត្រូវនៃការអនុវត្តការឃុំខ្លួនបណ្ដោះអាសន្នតាមច្បាប់ជាតិ។ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នដែលត្រូវចេញដោយចៅក្រមស៊ើបសួរតាមមាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវតែមានសម្អាងហេតុត្រឹមត្រូវចំពោះការសម្រេចឃុំខ្លួនដោយចង្អុលបង្ហាញពីមូលហេតុដូចដែលមានចែងក្នុងមាត្រា ២០៥ ដែលមានចំណុចដូចខាងក្រោម ៖

*"ការឃុំខ្លួនបណ្ដោះអាសន្នអាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្ដោះអាសន្ននេះជាការចាំបាច់ ៖*

*១. ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី។*

*២. ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។*

*៣. ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។*

*៤. ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។*

*៥. ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ។*

*៦. ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស។*

ក្រមនីតិវិធីព្រហ្មទណ្ឌអនុញ្ញាតឱ្យចៅក្រមស៊ើបសួរសម្រេចធ្វើការឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នរហូតដល់រយៈពេល ១៨ ខែ មានន័យថា ការឃុំខ្លួនបណ្ដោះអាសន្នម្ដងមានរយៈពេល ៦ ខែ (ចំពោះបទឧក្រិដ្ឋ) ហើយអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នបានពីរដង។[6] ការពន្យារឃុំខ្លួនបណ្ដោះអាសន្នសម្រាប់រយៈពេល ៦ ខែបន្ថែមទៀតក៏ត្រូវតែបញ្ជាក់ពីសម្អាងហេតុឱ្យបានត្រឹមត្រូវដោយយោងតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងមាត្រា ២០៥។[7]

## ៤. ការវិភាគជុំវិញការអនុវត្តច្បាប់នៅលើអង្គហេតុ

[6] មាត្រា ២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[7] មាត្រា២១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

## ៤.១ សេចក្តីសម្រេចដំបូងអំពីការបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន

នៅក្នុងសវនាការជំនុំជម្រះលើការឃុំខ្លួននៅថ្ងៃទី២ ខែឧសភា ចៅក្រមស៊ើបសួរបានលើកឡើងថា ដោយផ្អែកលើអង្គហេតុដែលថាបុគ្គលិកសមាគមអាដហុកចំនួនបួននាក់ «បានប្រព្រឹត្តបទល្មើស» ដូច្នេះហើយត្រូវតែធ្វើការឃុំខ្លួនអ្នកទាំងនេះ ដោយយោងតាមមាត្រា ២០៥ (១) (៤) និង (៥) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ប៉ុន្តែចៅក្រមពុំបានផ្តល់ភស្តុតាងគាំទ្រនូវអំណះអំណាងទាំងនេះឡើយ។ ម្យ៉ាងទៀត ការអះអាងពីពិរុទ្ធភាព ដែលជាផ្នែកសំខាន់គាំទ្រដល់សេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរក្នុងការឃុំខ្លួនពិតជាពុំបានគោរពដល់ការសន្មតជាមុនថាគ្មានទោស។

ដីកាបង្គាប់ឱ្យឃុំខ្លួននៅថ្ងៃទី២ ខែឧសភា ដែលត្រូវបានចេញយោងតាមមាត្រា២០៦ នៃក្រម នីតិវិធីព្រហ្មទណ្ឌ ដែលបញ្ជាក់ជាថ្មីម្តងទៀតថា លក្ខណៈវិនិច្ឆ័យដែលពាក់ព័ន្ធចំនួនបីនៃលក្ខណៈវិនិច្ឆ័យដែលពាក់ព័ន្ធសម្រាប់ការអនុវត្តការឃុំខ្លួនបណ្តោះអាសន្នក្រោមមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវបានបំពេញ។ ប៉ុន្តែ ដូចបានគូសបញ្ជាក់ពីខាងលើ គ្មានភស្តុតាងណាមួយសម្រាប់បញ្ជាក់ពីការឃុំខ្លួនស្របតាមលក្ខណៈវិនិច្ឆ័យត្រូវបានបង្ហាញនៅក្នុងតុលាការឡើយ។

## ៤.២ ការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន

ការបន្តការឃុំខ្លួនបណ្តោះអាសន្នក៏ត្រូវមានសម្អាងហេតុដែរ ឬបើពុំដូច្នោះទេនឹងចាត់ទុកថាជាការឃុំខ្លួនតាមអំពើចិត្ត។[8] មាត្រា ២១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា ការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្នត្រូវតែមានសម្អាងហេតុដោយយោងតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងមាត្រា២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ដីកាបង្គាប់ឱ្យពន្យារការឃុំខ្លួនអ្នកទាំង៥នេះត្រូវបានធ្វើឡើងក្រោមហេតុផលនៃការពន្យារពេលឃុំខ្លួនដោយផ្អែកលើមូលដ្ឋាននៃភាពចាំបាច់ដើម្បីបង្ការការជ្រៀតជ្រែកណាមួយរវាងសាក្សី ឬជនរងគ្រោះ ឬក៏បង្ការការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត ហើយនិងដើម្បីធានាថាជនត្រូវចោទត្រូវបានរក្សាទុកសម្រាប់តុលាការចាត់ការតាមនីតិវិធី (មាត្រា២០៥ (២) និង(៥) នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ នៅថ្ងៃទី១១ ខែវិច្ឆិកា សាលាឧទ្ធរណ៍បានតម្កល់សេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរដោយផ្អែកលើមាត្រា២០៥(២)។ ប៉ុន្តែ នៅតែពុំមានភស្តុតាងដើម្បីធ្វើជាសម្អាងហេតុបញ្ជាក់ពីភាពចាំបាច់ក្នុងការរារាំងការត្រូវរ៉ូវគ្នា ឬការជ្រៀតជ្រែកដែលតម្រូវដោយមាត្រា២០៥(២) នោះឡើយ។

## ៤.៣ ការវិភាគអំពីលក្ខណៈវិនិច្ឆ័យទាំងប្រាំមួយក្នុងមាត្រា ២០៥

---

[8] គណៈកម្មាធិការសិទ្ធិមនុស្ស, ខេរ៉ុក និង អូស្ត្រាលី (ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩) កថាខណ្ឌទី ៩.៣។

បើទោះជាមានទឡ្ហីករណ៍ផ្សេងៗគ្នាជាច្រើនត្រូវបានលើកឡើងនៅក្នុងដីកាបង្គាប់ឱ្យឃុំខ្លួន សវនាការ និង សេចក្តីសម្រេចយ៉ាងណាក្តី ការវិភាគទៅលើអង្គហេតុជុំវិញការចាប់ និងឃុំខ្លួនអ្នកទាំងប្រាំ ព្រមទាំងការចោទប្រកាន់ទៅលើពួកគាត់ បង្ហាញថា ពុំមានលក្ខណៈវិនិច្ឆ័យណាមួយសម្រាប់ការឃុំខ្លួនបណ្តោះអាសន្នតាមផ្លូវច្បាប់ក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងប្រាំមួយចំណុចអាចអនុវត្តក្នុងករណីនេះឡើយ។ លក្ខណៈវិនិច្ឆ័យទាំងនេះគ្រាន់តែអាចជាមូលហេតុដែលអាចអនុវត្តការឃុំខ្លួនបណ្តោះអាសន្នតាមច្បាប់ជាតិតែប៉ុណ្ណោះ។ ជាលទ្ធផល អាចពុំមានសម្អាងហេតុតាមផ្លូវច្បាប់សម្រាប់ការបន្តការឃុំខ្លួនបណ្តោះអាសន្ន។

*i. ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី*

អ្នកទាំងប្រាំនៅតែអះអាងថាពួកគាត់គ្មានទោសកំហុសព្រហ្មទណ្ឌតាមការចោទប្រកាន់នោះឡើយ ហេតុដូច្នោះហើយ ក៏គ្មានហេតុផលណាមួយដែលអាចជឿថាពួកគាត់នឹងប្រព្រឹត្តអំពើល្មើសផ្សេងនៅពេលអនាគតនោះដែរ។ ម្យ៉ាងទៀត អ្នកទាំងប្រាំត្រូវបានចោទប្រកាន់ទាក់ទងទៅនឹងសំណុំរឿងស៊ើបអង្កេតព្រហ្មទណ្ឌដ៏ចម្រូងចម្រាសមួយ ដែលមានការចាប់អារម្មណ៍ខ្លាំងពីសាធារណជន និងបណ្តាញព័ត៌មាន ដោយសារមានជាប់ពាក់ព័ន្ធជាមួយអនុប្រធានស្តីទីគណបក្សជំទាស់។ ស្ថិតនៅក្រោមការឃ្លាំមើលដ៏ស្វិតស្វាញពីសំណាក់អាជ្ញាធរ និងការដឹងឮយ៉ាងច្រើនដោយសារភាពសកម្មរបស់ខ្លួន និងការតស៊ូមតិក្នុងរឿងសិទ្ធិមនុស្សក្នុងនាមជាបុគ្គលិកសមាគមអាដហុក វាមិនទំនងទាល់តែសោះថាអ្នកទាំងប្រាំនឹងចូលរួមក្នុងសកម្មភាពខុសច្បាប់ណាមួយ ប្រសិនជាត្រូវបានដោះលែងនោះ។ ម្យ៉ាងទៀត ប្រសិនបើបារម្ភថាអ្នកទាំងប្រាំអាចប្រព្រឹត្តបទល្មើសសារជាថ្មីនោះ ក្តីបារម្ភនេះអាចដោះស្រាយបានតាមរយៈការបង្គាប់ឱ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌសមស្រប និងដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

***ii. ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត***

ពុំមានភស្តុតាងបង្ហាញថាអ្នកទាំងប្រាំអាចនឹងយាយីសាក្សី ឬជនរងគ្រោះ ឬក៏ត្រូវរ៉ូវគ្នានោះឡើយ។ ដូចបានគូសបញ្ជាក់ខាងលើ ដោយគិតទៅលើករណីលិចធ្លោក្នុងសំណុំរឿងនេះ និងបុគ្គលដែលពាក់ព័ន្ធ ប្រការនេះរឹតតែបង្ហាញថាការយាយី ឬការត្រូវរ៉ូវគ្នាកាន់តែមិនទំនងទាល់តែសោះ។ ជាថ្មីម្តងទៀត ប្រសិនជាមានការបារម្ភថាអ្នកទាំងប្រាំអាចនឹងពាក់ព័ន្ធក្នុងអំពើយាយីទៅលើសាក្សី ឬការត្រូវរ៉ូវគ្នា តុលាការអាចដោះស្រាយបានតាមរយៈការបង្គាប់ឱ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌសមស្រប និងដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលវិធានការនេះអាចនឹងរារាំងអ្នកទាំងនោះមិនឱ្យមានទំនាក់ទំនងជាមួយសាក្សី ឬជនត្រូវចោទដទៃទៀត។

*iii. ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ*

លក្ខណៈវិនិច្ឆ័យនេះមិនត្រូវបានចៅក្រមស៊ើបសួរ ឬសាលាឧទ្ធរណ៍លើកឡើងឡើយ និងក៏ពុំមានលើកឡើងនៅក្នុងដីកាបង្គាប់ឱ្យឃុំខ្លួនដែរ។ ពុំមានភស្តុតាងជាសម្ភារៈក្នុងករណីនៃបទល្មើសដែលបានចោទប្រកាន់នេះទេ ក្រៅតែពីសេចក្តីថ្លែងការណ៍ផ្ទាល់មាត់របស់សាក្សី។

### *iv. ដើម្បីធានាថាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី*

ការឃុំខ្លួនបណ្តោះអាសន្នទាក់ទងទៅនឹងមាត្រានេះនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលមានកត្តាមួយចំនួនបង្ហាញថាជនត្រូវចោទអាចគេចខ្លួន រួមមាន ៖ ការប្រើវិធានការដើម្បីលាក់បំបាំងអតីតកាលរបស់ពួកគេ ការប្រើឈ្មោះមិនពិត ការប្តូរការងារ ឬទីតាំងច្រើនដង ការផ្តល់ព័ត៌មានមិនពិត ការបាត់ខ្លួនពីមុន ការរស់នៅក្នុងតំបន់ដោយមានអ្នកគាំទ្រច្រើន និងមានទំនាក់ទំនងស្និទ្ធជាមួយជនមានឥទ្ធិពល ការធ្វើដំណើរទៅក្រៅប្រទេសញឹកញាប់ និងមធ្យោបាយផ្នែកហិរញ្ញវត្ថុ។[9] សម្អាងហេតុទាំងអស់នេះហាក់ដូចជាពុំសមហេតុផលនៅក្នុងករណីនេះទេ។ មែនទែនទៅ ក្រោយពីមានការដោះលែងបណ្តោះអាសន្ននៅម៉ោង១១យប់ នៅថ្ងៃទី២៧ ខែមេសា បន្ទាប់ពីការសាកសួរនៅអង្គភាពប្រឆាំងអំពើពុករលួយ អ្នកពាក់ព័ន្ធចំនួនបីនាក់ក្នុងចំណោមអ្នកទាំងនោះបានបង្ហាញខ្លួនជាថ្មីម្តងទៀតដើម្បីចូលខ្លួនឆ្លើយបំភ្លឺនៅវេលាម៉ោង ៨ ព្រឹកនៅថ្ងៃបន្ទាប់តាមការតម្រូវ។ លើសពីនេះ ដោយសារអ្នកទាំងប្រាំមានសមាជិកគ្រួសាររស់នៅប្រទេសកម្ពុជា ក្នុងនោះមានទាំងកូនតូចៗផងដែរ ដូច្នេះហានិភ័យដែលថាអ្នកទាំងនេះអាចគេចខ្លួនទៅក្រៅប្រទេសមានកម្រិតទាបបំផុត។ ប្រសិនជាតុលាការពិតជាបារម្ភថា អ្នកទាំងនេះអាចព្យាយាមគេចខ្លួនពីប្រទេសកម្ពុជា តុលាការអាចធ្វើការរឹតត្បិតអ្នកទាំងប្រាំក្នុងការធ្វើដំណើរនៅពេលអនុញ្ញាតឱ្យស្ថិតនៅក្រៅឃុំ ដូចជា ការដកហូតលិខិតឆ្លងដែនជាបណ្តោះអាសន្ន និងការតម្រូវឱ្យរាយការណ៍ជាប្រចាំទៅដល់ប៉ុស្តិ៍នគរបាលនៅមូលដ្ឋានរបស់ខ្លួន។

### *v.* ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ

ដូចបានគូសបញ្ជាក់ខាងលើ ការឃុំខ្លួនបណ្តោះអាសន្នទាក់ទងទៅនឹងមាត្រានេះនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលថានៅពេលពុំមានភស្តុតាងបង្ហាញថាអាចនឹងមានការគំរាមជាក់លាក់ណាមួយដល់សន្តិសុខរបស់ជនត្រូវចោទ

---

[9] សំណុំរឿងឌុច, ការប្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន, អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា («អ.វ.ត.ក»), អង្គបុរេជំនុំជម្រះ, ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧, កថាខណ្ឌទី ៣៧-៤០ (ឈ្មោះមិនពិត និងការធ្វើដំណើរ)។ សំណុំរឿង អៀង ធីរិទ្ធ, ការប្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន, អ.វ.ត.ក, អង្គបុរេជំនុំជម្រះ, ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨, កថាខណ្ឌទី ៥៤-៥៦ (ការរស់នៅក្នុងតំបន់ដែលមានអ្នកគាំទ្រច្រើន និងមានទំនាក់ទំនងជាមួយជនមានឥទ្ធិពល ការធ្វើដំណើរទៅក្រៅប្រទេសញឹកញាប់ មធ្យោបាយផ្នែកហិរញ្ញវត្ថុ)។ សំណុំរឿង អៀង សារី, ការប្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន, អ.វ.ត.ក, អង្គបុរេជំនុំជម្រះ, ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨, កថាខណ្ឌទី ១០២-១០៤ (ការធ្វើដំណើរទៅក្រៅប្រទេសញឹកញាប់ មធ្យោបាយហិរញ្ញវត្ថុ ទំនាក់ទំនងជាមួយអ្នកមានឈ្មោះល្បី និងអ្នកនយោបាយ)។

ទេនោះ ជនត្រូវចោទមិនអាចត្រូវបានឃុំខ្លួនបណ្តោះអាសន្នដោយផ្អែកលើមូលហេតុនេះឡើយ។[10] ពុំមានភស្តុតាងបង្ហាញពីការគំរាមកំហែងជាក់លាក់ណាមួយនៃករណីនេះត្រូវបានបង្ហាញនៅចំពោះមុខតុលាការឡើយ។ ហាក់ដូចជាមានហានិភ័យតិចតួចដែលអាចកើតចេញពីអង្គហេតុ និងបរិបទជុំវិញ ដែលថាអ្នកការពារសិទ្ធិមនុស្សទាំងប្រាំអាចនឹងប្រឈមនឹងគ្រោះថ្នាក់នៅក្នុងអំឡុងពេលឆ្ពោះទៅការជំនុំជម្រះ។ ជាការពិតទៅ ហាក់ដូចជាស្ថានភាពពន្ធនាគារមិនល្អដែលអ្នកជាប់ឃុំទាំងនេះបាននឹងកំពុងតែប្រឈមរយៈពេលជាងប្រាំពីរខែកន្លងមកនេះ កំពុងតែប៉ះពាល់ដល់សុខុមាលភាពរបស់ពួកគាត់ខ្លាំងជាងការដោះលែងពួកគាត់ឱ្យនៅក្រៅឃុំទៅទៀត។

### *vi.* ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ

លក្ខណៈវិនិច្ឆ័យនេះត្រូវបានលើកឡើងដោយចៅក្រមស៊ើបសួរនៅក្នុងដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នលើកដំបូងចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦។ ទោះជាយ៉ាងណា ពុំមានអង្គហេតុ ឬភស្តុតាងដែលថា ការដោះលែងអ្នកទាំងប្រាំអាចនឹងបង្កការរំខានដល់សណ្តាប់ធ្នាប់សាធារណៈ ដែលត្រូវដាក់បញ្ចូលនៅក្នុងដីកាបង្គាប់ឱ្យឃុំខ្លួននេះឡើយ ហើយក៏ពុំបានដេញដោលពីបញ្ហានេះនៅក្នុងសវនាការដែរ។ ការដោះលែងឱ្យនៅក្រៅឃុំចំពោះអ្នកទាំងបួនដែលខិតខំលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងនីតិរដ្ឋ ព្រមទាំងការដោះលែងអ្នកទីប្រាំដែលជាសមាជិកឯករាជ្យមួយរូបដ៏សំខាន់នៅក្នុងស្ថាប័នស្នូលមួយរបស់រដ្ឋ ហាក់ដូចជាគ្មានហានិភ័យដែលថាការដោះលែងអ្នកទាំងប្រាំនេះអាចនឹងបង្កការរំខានដល់សណ្តាប់ធ្នាប់សាធារណៈនោះឡើយ។

ជារួម ផ្អែកលើការវាយតម្លៃទៅលើបទប្បញ្ញត្តិច្បាប់ដែលពាក់ព័ន្ធ ករណីនេះបង្ហាញថា ពុំមានសម្អាងហេតុបញ្ជាក់ឱ្យបានត្រឹមត្រូវជុំវិញមូលដ្ឋានទាំងឡាយ ដែលបានលើកឡើងនៅក្នុងការវិភាគនេះដើម្បីអនុវត្តការឃុំខ្លួនបណ្តោះអាសន្នទៅលើអ្នកទាំងប្រាំក្នុងរយៈពេលយូរយ៉ាងនេះឡើយ។ ការខកខានរបស់អាជ្ញាធរកម្ពុជាក្នុងការលើកឡើងពីសម្អាងហេតុឱ្យបានគ្រប់គ្រាន់ និងភស្តុតាងគាំទ្រសម្រាប់ការឃុំខ្លួនអ្នកទាំងប្រាំ គឺជាការអនុវត្តខុសពីក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ការឃុំខ្លួនអ្នកទាំងប្រាំគឺអនុវត្តទៅដោយពុំមានមូលដ្ឋានច្បាប់គ្រប់គ្រាន់ស្របតាមច្បាប់ជាតិ ហេតុនេះជាការឃុំខ្លួនតាមតែអំពើចិត្ត និងមិនស្របច្បាប់ ដែលជាការរំលោភទៅលើរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

## សេចក្តីសន្និដ្ឋាន

ស្របពេលដែលការឃុំខ្លួនបណ្តោះអាសន្ននេះមិនស្របនឹងច្បាប់ជាតិ ការពន្យារពេលឃុំខ្លួនបណ្តោះអាសន្នទៅលើអ្នកទាំងប្រាំក៏អនុវត្តខុសពីបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែលមានអានុភាពអនុវត្តដោយផ្ទាល់នៅក្នុង

---

[10] សំណុំរឿង អៀង ធីរិទ្ធ ៖ ការប្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន, អ.វ.ត.ក, អង្គបុរេជំនុំជម្រះ, ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌទី ៦០-៦៣។

ច្បាប់ជាតិ។ ដូចបានលើកឡើងខាងលើ ពុំមានសម្អាងហេតុតាមផ្លូវច្បាប់គ្រប់គ្រាន់សម្រាប់ការអនុវត្តការឃុំខ្លួន ឬពន្យារពេលនៃការឃុំខ្លួនទៅលើអ្នកទាំងប្រាំ ព្រមទាំងបដិសេធសំណើសុំនៅក្រៅឃុំរបស់ពួកគាត់ដោយគ្មានសម្អាងហេតុសមស្រប។ តុលាការកម្ពុជាពុំបានផ្តល់សម្អាងហេតុ ឬភស្តុតាងគ្រប់គ្រាន់សម្រាប់ការអនុវត្តការឃុំខ្លួននេះឡើយ។ ដូច្នេះ យើងអាចនិយាយបានថា ទាំងការឃុំខ្លួនលើកដំបូងទៅលើអ្នកទាំងប្រាំ និងការបន្តឃុំខ្លួន ព្រមទាំងការពន្យារពេលនាពេលថ្មីនេះ អាចត្រូវបានចាត់ទុកថាជាការឃុំខ្លួនតាមអំពើចិត្ត និងមិនស្របច្បាប់ ដែលជាការរំលោភទៅលើមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៩ នៃ ក.អ.ស.ព.ន។ ក្នុងគោលបំណងដើម្បីធ្វើឱ្យស្ថានភាពរបស់អ្នកទាំងប្រាំស្របតាមច្បាប់ជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ អ្នកជាប់ឃុំទាំងប្រាំគួរតែត្រូវដោះលែងជាបន្ទាន់។

ចំពោះព័ត៌មានបន្ថែម សូមទំនាក់ទំនង ៖

| ល.រ | នាមអង្គការសង្គមស៊ីវិល | នាមអ្នកចូលរួម | លេខទំនាក់ទំនង |
|---|---|---|---|
| *១* | *ក្រុមការងារដើម្បីដោះស្រាយទំនាស់* | *កញ្ញា ស្រី សុធាវី* | *017 990 371* |
| *២* | *អនាគតយុវជនកម្ពុជាអាស៊ាន* | *លោក ស្រ៊ុន ស្រ៊ន* | *093 600 234* |
| *៣* | *មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា* | *លោក ឌុច ពិសិដ្ឋ* | *012 712 371* |
| *៤* | *សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា* | *កញ្ញា អាលម៉ាស ធីហ្វីរ៉ា* | *077 55 44 60* |
| *៥* | *គណៈកម្មាធិការ ដើម្បីការបោះឆ្នោត ដោយសេរី និងយុត្តិធម៌នៅកម្ពុជា* | *លោក គល់ បញ្ញា* | *012 942 017* |
| *៦* | *មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍* | *លោក ញ៉ឹក សារិន* | *012 800 561* |
| *៧* | *អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា* | *លោកស្រី រស់ សុភាព* | *012 627 857* |
| *៨* | *ក្រុមការងារពិសេសសិទ្ធិលំនៅឋាន* | *លោក សៀ ភារម្យ* | *012 852 325* |
| *៩* | *ជំនួយផ្នែកច្បាប់នៃកម្ពុជា* | *លោក រុន សាក៉យ* | *012 838 341* |
| *១០* | *អង្គការពន្លកខ្មែរ* | *លោក អាង ជាតិឡោម* | *012 517943* |
| *១១* | *អង្គការស្ត្រីខ្មែរ* | *លោកស្រី អរុណោ រស្មី* | *012 236 653* |
| *១២* | *អង្គការពិភពលោកប្រឆាំងទារុណកម្ម* | | |